# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការសាលាឧទ្ធរណ៍
លេខ ៤៤១/២០០១

## អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ភ្នំពេញ

**ជម្រាបមក**

**លោកព្រះរាជអាជ្ញាតុលាការខេត្តសៀមរាប ឧត្តមានជ័យ**

**សូមជ្រាប។**

**កម្មវត្ថុ:** របៀបចោទប្រកាន់ និងសម្រេចលើករណីសហចារី រួមប្រព្រឹត្តបទល្មើសគេចខ្លួន ។

ខ្ញុំបានសង្កេតឃើញ ក្នុងសំណុំរឿងចំនួនពីរ (២) មកហើយ ដែលអយ្យការបានធ្វើការចោទប្រកាន់ជូនទៅចៅក្រមស៊ើបអង្កេត ហើយនៅពេលបញ្ចប់នីតិវិធី លើកយកមកសម្រេចបង្គង់បណ្តឹងអាជ្ញា ឧទាហរណ៍ ដូចជាការសម្រេចនៅក្នុងសំណុំរឿងលេខ ៤០៤ ចុះថ្ងៃទី១២-០៨-៩៩ ដែលមានជនត្រូវចោទ ៖

-ឈ្មោះ ស៊ុន ណាង មានខ្លួន ពីបទប្លន់ និងបង្ករបួសស្នាម

-ឈ្មោះ អឿ សារឿង មានខ្លួន ពីបទប្លន់ និងបង្ករបួសស្នាម

-ឈ្មោះ សុខ សំណាង មានខ្លួន ពីបទប្លន់ និងបង្ករបួសស្នាម

-ឈ្មោះ កែវ ថាវ គេចខ្លួន ពីបទប្លន់ និងបង្ករបួសស្នាម

-ឈ្មោះ លីម ភក្តី គេចខ្លួន ពីបទប្លន់ និងបង្ករបួសស្នាម

-ឈ្មោះ ង៉ែត ណូន មានខ្លួន ពីបទរក្សាទុកអាវុធ ។

នៅក្នុងសំណុំរឿងនោះ ចៅក្រមស៊ើបអង្កេត ក្រោយទទួលការដោះសាររបស់ជនត្រូវចោទមានខ្លួន (គ្មានមេធាវី) បានសម្រេចឃុំខ្លួន និងក្រោយចាត់វិធានការទទួលបប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទទួលយកចម្លើយសាក្សី បំពេញនីតិវិធីចោទប្រកាន់ក្នុងបទល្មើសថ្មីបន្ថែម ប៉ុន្តែគ្មានចំណាត់ការអ្វីឬចដើរឱ្យចូលខ្លួន ឬឱ្យនាំខ្លួន ចំពោះជនល្មើសឈ្មោះ កែវ ថាវ និងលឹម ភ័ក្ត្រ គេចខ្លួននោះសោះ ស្រាប់តែបញ្ចប់នីតិវិធីស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅអយ្យការហើយអយ្យការ ក៏សម្រេចបញ្ជូនខ្លួនជនល្មើសមានខ្លួនទៅតុលាការជំនុំជម្រះនិងសម្រេចបង្គង់បណ្តឹងអាជ្ញាលើជនល្មើសគេចខ្លួន ដោយមិនធ្វើការសន្និដ្ឋានឱ្យចៅក្រមស៊ើបអង្កេត ចេញដីកាចាប់ខ្លួនជនល្មើសនេះ ទោះជាមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាអ្នកទាំងនេះសុទ្ធតែជាសហចារី រួមប្រព្រឹត្តបទប្លន់ដៃរក្តិ ។

ចំណាត់ការរបៀបនេះ ជាការបញ្ចប់នីតិវិធីស៊ើបអង្កេត ដែលជនល្មើសដែលបានប្រព្រឹត្តបទល្មើសអយ្យការបានធ្វើការចោទប្រកាន់រួចហើយ បានទទួលផុតការចោទប្រកាន់ ដោយគ្មាននីតិវិធីអ្វីទៅរំខានតទៅអនាគតទៀតឡើយ ។

ដូច្នេះដើម្បីអាចជៀសវាងការខ្វះចន្លោះក្នុងនីតិវិធី ដែលអយ្យការបានធ្វើការចោទប្រកាន់ហើយចៅក្រមស៊ើបអង្កេតបានទទួលសេចក្តីសន្និដ្ឋានឱ្យចេញដីកាចាប់ខ្លួន បានចេញដីកាចាប់ខ្លួនជនល្មើសរួចហើយ អយ្យការមិនត្រូវធ្វើសេចក្តីសម្រេចបង្គង់បណ្តឹងអាជ្ញាទេ ត្រូវតែចៅក្រមស៊ើបសួរខ្លួនឯងធ្វើសេចក្តីសម្រេចក្នុងដីកាបញ្ចប់ការស៊ើបសួរ (ដែលមាន សេចក្តីសម្រេចជូនជនល្មើសទៅតុលាការទៅជំនុំជម្រះលើកលែងចោទប្រកាន់) និងសម្រេចបង្អង់ការស៊ើបអង្កេតចំពោះជនល្មើសគេចខ្លួនទុកមួយអន្លើសិន ពីព្រោះទៅថ្ងៃមុខទៀតបើមានការចាប់ខ្លួនបានហើយ

បញ្ជូនខ្លួនមកតុលាការ អយ្យការមិនបាច់ធ្វើការចោទប្រកាន់ជាថ្មីទេ គឺចៅក្រមស៊ើបអង្កេតដដែលធ្វើកាសម្រេចលើក យករឿងចាស់របស់ខ្លួន មកចាត់ការស៊ើបអង្កេតចំពោះជនល្មើសក្រោយនេះបន្ត និងបញ្ចប់ទៅតាមនីតិវិធីធម្មតាតទៅ

គួរធ្វើការវែកញែកថា ជនល្មើសគេចខ្លួនបានចាកចេញពីអសយដ្ឋានត្រឹមត្រូវតាមច្បាប់របស់ខ្លួនដោយគ្មាន បំពេញបែបបទរដ្ឋបាលបានសេចក្តីថា បានបោះបង់នូវសិទ្ធិការពារចំពោះមុខតុលាការដូច្នេះបើមានសាវតាជាតិជន ល្មើសនេះគ្រប់គ្រាន់ ដែលបញ្ជាក់ថាមិនអាចឱ្យប្រទ្បំមនុស្សបានទេគួរតែអយ្យការសន្និដ្ឋានឱ្យបញ្ជូនជននេះទៅ តុលាការជំនុំជម្រះតែម្តង ។

គួរធ្វើការកត់សម្គាល់ផងដែរថា ការប្រព្រឹត្តអំពើហិង្សាក្នុងឱកាសប្រព្រឹត្តអំពើប្លន់ជាលក្ខខ័ណ្ឌទម្ងន់ទោស នៃ អំពើប្លន់នេះប៉ុណ្ណោះ ប៉ុន្តែមិនមែនជាបទល្មើសដោយឡែកទេ។ការទទួលបញ្ញើនូវអាវុធ ដើម្បីរក្សាសុវត្ថិភាពជាអំពើ សមគំនិតក្នុងបទរក្សាអាវុធទុកខុសច្បាប់ ពុំមែនជាអំពើប្រព្រឹត្តបទល្មើសរក្សាអាវុធទុកខុសច្បាប់នេះទេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០១

**អគ្គព្រះរាជអាជ្ញា**

**ហាន់រ៉ូ វ៉ាកេន**

<u>ចម្លងជូន</u>

-ឯកឧត្តម រដ្ឋមន្រ្តីក្រសួងយុត្តិធម៌

-ឯកឧត្តម អគ្គព្រះរាជអាជ្ញាតុលាការកំពូល

-គ្រប់ព្រះរាជអាជ្ញាតុលាការខេត្ត-ក្រុង

-ដើម្បីជ្រាបជាព័ត៌មាន

-ឯកសារ-កាលប្បវត្តិ